ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៤៣ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២០១/១៥ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការ ធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ០៧ អនក្រ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី» ៥

# សំរេច

ប្រការ ១-

បោះផ្សាយសញ្ញាប័ណ្ណរដ្ឋ សំរាប់បំពេញដើមទុនអោយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី» ក្នុងកំរិតទឹកប្រាក់ចំនួន ២៧.៩០០.០០០.០០០៛ (ម្ភៃប្រាំពីពាន់ប្រាំបួនរយលានរៀល) និងបន្ថែមជាសាច់ប្រាក់សុទ្ធចំនួន ១០០.០០០.០០០៛ (មួយរយលានរៀល) ដើម្បីអោយគ្រប់ចំនួន ២៨.០០០.០០០.០០០៛ ។ ទន្ទឹមគ្នានេះដែរក្រុមហ៊ុនកម្ពុជារី ត្រូវផ្តល់នូវប័ណ្ណភាគហ៊ុនរបស់ខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុបស្មើ ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ដែលក្នុងនោះមាន ២៨០.០០០ប័ណ្ណភាគហ៊ុន (ពីររយប៉ែតសិបពាន់ប័ណ្ណភាគហ៊ុន) និងមានតម្លៃនាមចរឹកក្នុងមួយឯកតា ១០០.០០០៛ (មួយរយពាន់រៀល) ។

ប្រការ ២-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ចំនួន ២.៧៩០ ប័ណ្ណ (ពីរពាន់ប្រាំពីររយកៅសិបប័ណ្ណ) ដែលមានតម្លៃនាមចរឹកក្នុងមួយឯកតា ១០.០០០.០០០៛ (ដប់លានរៀល) ។

ប្រការ ៣-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយសំរាប់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) តាមឥណប្រតិទានកំណត់ក្នុងសញ្ញាប័ណ្ណ ។ ក្នុងរយៈពេលបីឆ្នាំនេះ អ្នកកាន់សញ្ញាប័ណ្ណ នឹងត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% (បីភាគរយ) ហើយការទូទាត់ការប្រាក់នេះត្រូវធ្វើឡើងជារៀងរាល់ ០៦ ខែ (ប្រាំមួយខែ) ម្តង ដោយឈរលើមូលដ្ឋាន ០៦ ខែ ស្មើ ១៨០ ថ្ងៃ និង មួយឆ្នាំ ស្មើ ៣៦០ ថ្ងៃ ។

ប្រការ ៤-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធធ្វើសំណងសញ្ញាប័ណ្ណរដ្ឋមុនឥណប្រតិទានដែលបានកំណត់ក្នុងសញ្ញាប័ណ្ណ គឺអាស្រ័យដោយស្ថានភាពថវិការបស់រដ្ឋ ។

ប្រការ ៥-

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាប័ណ្ណរដ្ឋ ព្រមទាំងធ្វើរបាយការណ៍ជូននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងបំណុល) ។

ប្រការ ៦-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ចម្លងជូន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា- ឯកសារ- កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់